ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៦៦៧ អយក. ឯក

ថ្ងៃ ចន្ទ ៩រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២៤

**ជម្រាបជូន**

- **ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គាធិការ**
- **ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយកវិទ្យាស្ថាន**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង**
- **លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS ) លើមុខងារគ្រប់គ្រងបេសកកម្មក្នុងនិងក្រៅប្រទេសនៅតាមអង្គភាពថវិការដ្ឋបាលថ្នាក់កណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង ៖** លិខិតលេខ៦៣៥អយក.ហរ ចុះថ្ងៃទី០៩ខែកក្កដាឆ្នាំ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានអង្គភាពជ្រាបថាៈ ក្រសួង បានកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារគ្រប់គ្រងបេសកកម្មក្នុងនិងក្រៅប្រទេសដែលមានលក្ខណៈជា Web Application(Online) ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាឱ្យកាន់តែមានសុក្រឹតភាព គណនេយ្យភាព និងប្រសិទ្ធភាព ជាពិសេសប្រព័ន្ធមានសមត្ថភាពក្នុងការកត់ត្រាចំណាយដោយផ្សារភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងសូចនាករសមិទ្ធកម្ម ព្រមទាំងផលិតបាននូវរបាយការណ៍សម្រាប់ទូទាត់ជាច្រើនប្រភេទតាមតម្រូវការប្រើប្រាស់ជាក់ស្តែង ហើយបានជួយសម្រួលការងារបានជាអតិបរិមាជូនមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុឱ្យកាន់តែប្រសើរជាងមុន។ ក្នុងន័យនេះ ក្រសួងសូមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា( EFMS )លើមុខងារគ្រប់គ្រងបេសកកម្មក្នុងនិងក្រៅប្រទេសជូនអង្គភាពថវិការដ្ឋបាលថ្នាក់កណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសម្រាប់ប្រើប្រាស់ជាផ្លូវការចាប់ពីឆ្នាំ២០២៤ តទៅ។

(ទំព័រ១)

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ជាប្រធានអង្គភាព ចវិកាមេត្តាជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូនៈ**
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
 " ដើម្បីជ្រាបជាព័ត៌មាន "
-កាលប្បវត្តិ
-ឯកសារ .នា. ហិរញ្ញវត្ថុ